 គាំទ្រមូលនិធិដោយ៖

SPIDER

អនុវត្តគម្រោងដោយ៖

អង្គការទិន្នន័យអំពីការអភិវឌ្ឍ Open Development Cambodia

ធនធានអប់រំឌីជីថលជាភាសាជនជាតិដើមភាគតិចនៅកម្រិតបឋមសិក្សា

គម្រោងធនធានអប់រំឌីជីថលជាភាសាជនជាតិដើមភាគតិចនៅកម្រិតបឋមសិក្សា គឺជាគម្រោងដែលគាំទ្រមូលនិធិដោយកម្មវិធីរបស់ប្រទេសស៊ុយអែតសម្រាប់វិស័យអាយស៊ីធីនៅក្នុងតំបន់កំពុងអភិវឌ្ឍ (SPIDER)។

ទិដ្ឋភាពទូទៅ

គម្រោងធនធានអប់រំឌីជីថលជាភាសាជនជាតិដើមភាគតិចនៅកម្រិតបឋមសិក្សា អនុវត្តដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) នៅខេត្តចំនួន៦មានដូចជាខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ និងព្រះវិហារ។ គម្រោងនេះផ្ដល់នូវដំណោះស្រាយដល់ឧបសគ្គខាងភាសានៃការអប់រំថ្នាក់ដំបូងដែលកើតឡើងចំពោះសិស្សជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា ដើម្បីកាត់បន្ថយការបោះបង់ការសិក្សា លុបបំបាត់វដ្តនៃភាពក្រីក្រ ការមិនរាប់បញ្ចូលនិងវិសមភាពក្នុងសង្គម ធ្វើឱ្យប្រសើរឡើងនិងគាំទ្រដល់ដំណើរការសិក្សារបស់សិស្ស និងចូលរួមជួយឱ្យគ្រូបង្រៀនកម្រិតបឋមទទួលបាននូវជំនាញ និងចំណេះដឹងផ្នែកឌីជីថល។ គម្រោងនេះមានយុទ្ធសាស្ត្រក្នុងការបង្កើតនូវបរិយាកាសសិក្សាប្រកបដោយប្រសិទ្ធភាពនិងគុណភាពតាមរយៈការផលិតវីដេអូនិងផតខាសធ៍អប់រំឌីជីថលជាភាសាជនជាតិដើមភាគតិច និងការជួយលើកកម្ពស់អក្ខរកម្មនិងជំនាញឌីជីថលរបស់គ្រូបង្រៀន។

គោលបំណង

បង្កើនលទ្ធភាពទទួលបានធនធានអប់រំឌីជីថលជាភាសាជនជាតិដើមភាគតិច៖ កាត់បន្ថយគម្លាតនិងបង្កើនធនធានអប់រំឌីជីថលជាភាសាជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា។

កែលម្អនិងលើកកម្ពស់ការសិក្សារៀនសូត្រនិងសមត្ថភាពឌីជីថលរបស់សិស្សជនជាតិដើមភាគតិចនៅកម្រិតបឋម៖ ផលិតវីដេអូអប់រំឌីជីថលចំនួន ៩០ ជាភាសាជនជាតិដើមភាគតិចចំនួន ៥ ភាសា។

ធ្វើឱ្យប្រសើរឡើងនិងលើកកម្ពស់ជំនាញនិងអក្ខរកម្មឌីជីថលរបស់គ្រូបង្រៀនកម្រិតបឋមសិក្សា៖ បណ្ដុះបណ្ដាលផ្ដល់ជំនាញឌីជីថលដល់គ្រូបង្គោលនៅក្នុងខេត្តគោលដៅដើម្បីប្រើប្រាស់ឧបករណ៍ និងសម្ភារៈក្នុងការបង្រៀនសិស្ស។

កាត់បន្ថយការបោះបង់ការសិក្សារបស់សិស្ស៖ លុបបំបាត់ហានិភ័យខ្ពស់នៃការមិនរាប់បញ្ចូល និងវិសមភាពក្នុងសង្គមតាមរយៈការបង្កើនលទ្ធភាពទទួលបានការអប់រំ។

www.opendevelopmentcambodia.net contact@opendevcam.net 023 902 196 @OpenDevCam @OpenDevCam

រយៈពេលអនុវត្តគម្រោង

ខែវិច្ឆិកា ឆ្នាំ២០២២ ដល់ ខែតុលា ឆ្នាំ២០២៣

អ្នកទទួលផល

ក. ដោយផ្ទាល់៖ សិស្សបឋមសិក្សាជាជនជាតិដើមភាគតិចចំនួន ១២.៥០០នាក់ និងគ្រូបឋមសិក្សាចំនួន ៨៤នាក់។

ខ. វេទិកាឌីជីថល៖ ចំនួនអ្នកមើលយ៉ាងតិច ៤៥.០០០ នៅលើយូធូប និងចំនួនអ្នកមើល ៤៥.០០០ នៅលើទំព័រហ្វេសប៊ុក និងវេបសាយអូឌីស៊ី។

គ. ដោយប្រយោល៖ មនុស្សពេញវ័យជនជាតិដើមភាគតិច រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលនិងការយកទៅបកប្រែជាភាសាជនជាតិដើមភាគតិចផ្សេងទៀត។

ទីតាំងអនុវត្តគម្រោង

គម្រោងនេះនឹងត្រូវអនុវត្តនៅក្នុងតំបន់ជនបទនៃខេត្តចំនួន៦៖ រតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ និងព្រះវិហារ។



សកម្មភាព

១. ការផលិត និងចែកចាយមាតិកាឌីជីថល

- ជ្រើសរើសប្រធានបទ និងខ្លឹមសារមេរៀនអប់រំ។
- ផលិតវីដេអូនិងផតខាសអប់រំចំនួន ៩០ ជាភាសាជនជាតិដើមភាគតិច ដែលបានជ្រើសរើសចំនួន ៥ ភាសា។
- ចែកចាយកញ្ចប់មាតិកាវីដេអូអប់រំឌីជីថលទៅកាន់សាលាកម្រិតបឋមសិក្សានៅក្នុងខេត្តដែលបានជ្រើសរើស។

២. ការកសាងសមត្ថភាព និងការបណ្តុះបណ្តាល

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា អង្គការជនជាតិដើមភាគតិច និងភាគីពាក់ព័ន្ធ។
- ធ្វើការវាយតម្លៃតម្រូវការឧបករណ៍ និងការផ្គត់ផ្គង់។
- រៀបចំសិក្ខាសាលាស្តីពីការបង្ហាញធនធានឌីជីថលថ្មីដល់ភាគីពាក់ព័ន្ធដែលរួមមានក្រសួងអប់រំ យុវជន និងកីឡា អង្គការជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិល។
- រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលដែលជាគ្រូបង្រៀននៅកម្រិតបឋមសិក្សានៅខេត្តចំនួន ៦ ដែលបានជ្រើសរើស។

៣. ការផ្សព្វផ្សាយ

- បង្ហាញគំនិតផ្តួចផ្តើមដល់សាលាបឋមសិក្សាដែលបានជ្រើសរើស។
- ផលិតធនធានអប់រំឌីជីថលក្នុងទម្រង់ច្បាស់លាស់និងងាយយល់។
- ផ្សព្វផ្សាយវីដេអូអប់រំ និងផតខាសនៅលើទំព័រហ្វេសប៊ុក យូធូប និងវេបសាយរបស់អូឌីស៊ី គេហទំព័រធនធានអប់រំកម្ពុជា របស់ក្រសួងអប់រំ យុវជន និងកីឡា និងវេបសាយវេទិកា អាយស៊ីធី និងឌីជីថលកម្ពុជា។
- បញ្ចាំងវីដេអូនៅសាលាឃុំ និងបណ្ណាល័យ។
- លើកកម្ពស់កិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធ។
- បោះពុម្ពផ្សាយសាច់រឿងជោគជ័យនៃគម្រោងលើវេបសាយ យូធូប និងហ្វេសប៊ុករបស់អូឌីស៊ី។

ព័ត៌មានទំនាក់ទំនង

PETRA RINDBY
ប្រធានគ្រប់គ្រងកម្មវិធី និងទំនាក់ទំនង | petra@spidercenter.org
កម្មវិធីរបស់ប្រទេសស៊ុយអែតសម្រាប់វិស័យអាយស៊ីធីនៅក្នុងតំបន់កំពុងអភិវឌ្ឍ (SPIDER)

លោក ធី ទ្រី
នាយកប្រតិបត្តិ/និពន្ធនាយក | contact@opendevcam.net
អង្គការទិន្នន័យអំពីការអភិវឌ្ឍ